ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
សំណុំរឿងព្រហ្មទណ្ឌលេខ:២៣៣
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
សាលក្រម
លេខ: ៥៩២ (ក)
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ស្ពឺ
បានបើកសវនាការជាសាធារណៈ
នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០
វេលាម៉ោង៩ និង០០ នាទីព្រឹក
ដោយមានសមាសភាពជំនុំជម្រះដូចតទៅ:

ចៅក្រមជំនុំជម្រះ
លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

តំណាងអយ្យការ
លោកស្រី [redacted] ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តកំពង់ស្ពឺ ។

ក្រឡាបញ្ជីសវនាការ
លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-លោក [redacted] មេធាវីការពារសិទ្ធិឲ្យ
ជនជាប់ចោទឈ្មោះ [redacted]វីសែន និងជនជាប់ចោទឈ្មោះ [redacted]វីសិដ្ឋ។
-លោក **ម៉ែន សុភាព** មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ យ៉ា ថារិទ្ធ (អវត្តមាន)។

ដើម្បីជំនុំជម្រះ
-សំណុំរឿងព្រហ្មទណ្ឌលេខ: ២៣៣ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ លើជនជាប់ចោទ៖
១.ឈ្មោះ [redacted]បូរី ហៅតឿ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅ
បច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ថាវ (ស) ម្តាយ
ឈ្មោះ [redacted] មន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីនួន (រ) គ្មានកូន ជានីតិជន ប្រវត្តិទោសពីមុន គ្មាន (ឃុំខ្លួន
២២៩/ ២៩.០២.២០)។
២.ឈ្មោះ [redacted]វីសែន ហៅ តែម ហៅ ពៅ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត
ភូមិ [redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្នភូមិអូរ

ក្រសារ ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហ៊ឺ (រ) ម្តាយឈ្មោះ [redacted] សុផន (រ) នៅលីវ ជានីតិជន ប្រវត្តិទោសពីមុន គ្មាន (ឃុំខ្លួន ២២៧/២៩.០២.២០)។

៣.ឈ្មោះ [redacted] **វិសិដ្ឋ ហៅ ពិសិដ្ឋ** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ [redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ន ភូមិអូរក្រសារ ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហ៊ឺ (រ) ម្តាយឈ្មោះ [redacted] សុផន (រ) ពោះម៉ាយ ជានីតិជន ប្រវត្តិទោសពីមុន គ្មាន (ឃុំខ្លួន ២២៦/២៩.០២.២០)។

៤.ឈ្មោះ [redacted] **ន** ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សេន (ស) ម្តាយឈ្មោះ [redacted] ឡេង (រ) ប្រពន្ធឈ្មោះ [redacted] នាថ (រ) ពោះម៉ាយ ជានីតិជន ប្រវត្តិទោសពីមុន គ្មាន (ឃុំខ្លួន ២២៥/២៩.០២.២០)។

៥.ឈ្មោះ [redacted] **ទ្រី** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] អឿន (ស) ម្តាយឈ្មោះ [redacted] សន (រ) ពោះម៉ាយ ជានីតិជន ប្រវត្តិទោសពីមុន គ្មាន (ឃុំខ្លួន ២២៨/២៩.០២.២០)។

៦.ឈ្មោះ [redacted] **ថារិទ្ធ** ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] យ៉ាត (រ) ម្តាយឈ្មោះ [redacted] សុង (រ) នៅលីវ ជាអនីតិជន ប្រវត្តិទោសពីមុន គ្មាន (មិនឃុំខ្លួន ៧០/២៩.០២.២០)។

-ដែលជាប់ចោទពីបទ: **ប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ **បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ**។

-បានឃើញ: របាយការណ៍សំយោគលេខ: ៣២/២០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ស្នងការនគរបាលខេត្តកំពង់ស្ពឺ។

-បានឃើញ: កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ: ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២២៥(ឃ) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted] **ន**។

-បានឃើញ: ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២២៦(ឃ) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted] ពិសិដ្ឋ ([redacted] វិសិដ្ឋ)។

-បានឃើញ: ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២២៧(ឃ) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted]វិសែន (ពៅ)(តែម)។

-បានឃើញ: ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២២៨(ឃ) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted]ទ្រី (ទ្រី)។

-បានឃើញ: ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២២៩(ឃ) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted]បូរី (តឿ)។

-បានឃើញ: ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៧០ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ លើឈ្មោះ [redacted]ថារិទ្ធ។

-បានឃើញ: ដីកាសន្និដ្ឋានស្តាពរលេខ ៣៩៥១ អ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ: ដីកាដំណោះស្រាយលេខ ៣៩៦ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៥១៩ ដចជ.រប/២០ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

-កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង១២ និង ៣០នាទី សមត្ថកិច្ចបានចុះបង្ក្រាបមុខសញ្ញាដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសគ្រឿងញៀននៅចំណុចភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ហើយបានដកហូតវត្ថុតាងមានម៉ូតូចំនួន ០៣គ្រឿង ទូរស័ព្ទដៃចំនួន ០២គ្រឿង កាំភ្លើងកែច្នៃចំនួន ០៤ដើម ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] បូរី, ឈ្មោះ [redacted]វិសែន, ឈ្មោះ [redacted]វិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ ពិតប្រាកដមែន។

<u>តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ</u>

-សិទ្ធិទទួលដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឲ្យចូលខ្លួន

-សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី និងធ្វើសំណូមពរផ្សេងៗ

-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវី

-សិទ្ធិសុំផ្លាស់ប្តូរសមាសភាពចៅក្រមជំនុំជម្រះ

<u>ឆាពេលសវនាការ</u>

-ក្រឡាបញ្ជីបានឡើងអានកំណត់ហេតុសូរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថារិទ្ធ នៅដំណាក់កាលចៅក្រមស៊ើបសួរមានខ្លឹមសារថា: សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ

ឆ្នាំ២០២០ ម៉ោង ១២ថ្ងៃត្រង់ ដោយពីល្ងាច ថ្ងៃទី២៤ ខ្ញុំបាទមានគ្នា ០៧នាក់ មានរូបខ្ញុំបាទ, ឈ្មោះ [redacted]វិសិដ្ឋ, ឈ្មោះ [redacted] ប៊ូរី, ឈ្មោះ [redacted] ន្ទូ, ឈ្មោះ [redacted]វីសែន, ឈ្មោះ [redacted] ទ្រី និងឈ្មោះ សាល ដោយឈ្មោះ [redacted]វីសែន បានចូលលុយគ្នាទិញគ្រឿងញៀនពីឈ្មោះ លីន ដោយទិញតម្លៃ ៣០,០០០ (បីម៉ឺន) រៀល ដោយឈ្មោះ លីន ជាអ្នកយកមកឱ្យដល់កន្លែងចំការតែម្តង ដោយឈ្មោះ សាល ជាម្ចាស់ចំការជាអ្នកទូរស័ព្ទទៅទិញ។ ខ្ញុំបាទធ្លាប់ស្គាល់ឈ្មោះ លីន ចំណែកឈ្មោះ វ៉ា ក៏ជាអ្នកលក់គ្រឿងញៀនដែរ តែខ្ញុំបាទមិនដែលទិញពីគាត់នោះទេ ដោយមិត្តភក្តិខ្ញុំបាទធ្លាប់ទៅទិញគ្រឿងញៀនពីឈ្មោះ វ៉ា ។ ខ្ញុំបាទដឹងថា នៅចំការរបស់ឈ្មោះ [redacted]វីសែន ជាកន្លែងទិញលក់គ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនដែរ ខ្ញុំបាទនៅទីនោះដោយជួយចាំចំការបងឈ្មោះ [redacted] វីសែន ដោយក្នុងមួយអាទិត្យខ្ញុំបាទប្រើប្រាស់គ្រឿងញៀន០៣ ទៅ០៤ដង ដោយបងឈ្មោះ សាល ជាអ្នកឱ្យខ្ញុំបាទប្រើប្រាស់។ នៅពេលសមត្ថកិច្ចទៅដល់ចំការរបស់ឈ្មោះ [redacted]វីសែន ឆែកឆេរឃើញមានកាំភ្លើងកែច្នៃចំនួន ០៥ដើម ជារបស់ម្ចាស់ចំការឈ្មោះ [redacted] វីសែន ឈ្មោះ [redacted] វិសិដ្ឋ និងឈ្មោះ សាល និងឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន ហើយសមត្ថកិច្ចឃាត់ខ្លួនពួកខ្ញុំបាទតែម្តង។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទមិនបានដកហូតអ្វីពីខ្ញុំបាទនោទេ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ[redacted] ប៊ូរី ហៅតឿ បានឆ្លើយថា: ខ្ញុំបាទសុំឆ្លើយដោយខ្លួនឯង ដោយពុំចាំបាច់មានមេធាវី នៅអមជាមួយនោះទេ។ សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១០ព្រឹក ដោយឈ្មោះ ម្រេច បានខ្ចីម៉ូតូរបស់ខ្ញុំបាទទៅភ្នំពេញ ហើយខ្ញុំបាទក៏ដេកក្នុងអង្រឹងចាំនៅចំការរបស់ឈ្មោះ[redacted]វីសែន ស្រាប់តែសមត្ថកិច្ចចុះទៅធ្វើការឆែកឆេរឃើញកាំភ្លើងចំនួន ០៥ដើម ជារបស់ឈ្មោះ [redacted]វីសែន, ឈ្មោះ វិសិដ្ឋ និងឈ្មោះ សាល ជាបងប្អូនបង្កើតគ្នា តែឈ្មោះ សាល រត់បាត់ហើយ និងឃើញមានឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន នៅចំការរបស់ឈ្មោះ[redacted]វីសែន, ឈ្មោះ[redacted]វិសិដ្ឋ និងឈ្មោះ សាល ហើយសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនតែម្តង។ ដោយកាលពីល្ងាចថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ខ្ញុំបាទបានប្រើប្រាស់គ្រឿងញៀនមានគ្នា ០៧នាក់ មានរូបខ្ញុំបាទ, ឈ្មោះ[redacted]វិសិដ្ឋ, ឈ្មោះ [redacted] ន្ទូ, ឈ្មោះ [redacted]ថារិទ្ធ, ឈ្មោះ [redacted]វីសែន, ឈ្មោះ [redacted] ទ្រី និងឈ្មោះ សាល ដោយបានចូលលុយគ្នាទិញគ្រឿងញៀនពីឈ្មោះ លីន ដោយទិញចំនួន ០១ កញ្ចប់ តម្លៃ ៣០,០០០ (បីម៉ឺន) រៀល ដោយឈ្មោះ លីន ជាអ្នកយកមកឱ្យដល់កន្លែងចំការតែម្តង ដោយឈ្មោះ សាល ជាអ្នកទូរស័ព្ទទៅទិញ។ ចំពោះឈ្មោះ វ៉ា ខ្ញុំបាទមិនស្គាល់ទេ ហើយខ្ញុំបាទទៅចំការរបស់ឈ្មោះ [redacted]វីសែន គឺខ្ញុំបាទដឹងថា កន្លែងនោះជាកន្លែងទិញលក់គ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនដែរ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទបានដកហូតទូរស័ព្ទម៉ាក (OPPO) ចំនួន ០១ គ្រឿង ក្រៅពីនេះ មិនមានដកហូតអ្វីផ្សេងទៀតទេ។ ខ្ញុំបាទប្រើប្រាស់គ្រឿងញៀនឃ្យូរៗម្តង ព្រោះធ្វើ

ការរោងចក្រមិនស្រួវបានប្រើប្រាស់នោះទេ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ [redacted]សែន ហៅ តែម ហៅ ពៅ បានឆ្លើយថា: សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១០ព្រឹក ដោយសារពួកខ្ញុំបាទទាំងអស់មានគ្នា ០៦នាក់ មានរូបខ្ញុំបាទ, ឈ្មោះ [redacted]វិសិដ្ឋ មិនមែន [redacted]ពិសិដ្ឋ ទេ, ឈ្មោះ [redacted]នូ, ឈ្មោះ [redacted] ថារិទ្ធ, ឈ្មោះ [redacted] ប៊ូរី និងឈ្មោះ [redacted] ទ្រី បាននាំគ្នាប្រើប្រាស់គ្រឿងញៀននៅក្នុងរោងចំការអំពៅរបស់ខ្ញុំបាទ ដោយគ្រឿងញៀនដែលប្រើប្រាស់នោះ គឺទិញពីឈ្មោះ លីន ចំនួន ០១កញ្ចប់ តម្លៃ ៣០,០០០ (បីម៉ឺន) រៀល ដោយពួកខ្ញុំបាទបានចូលលុយគ្នាទិញ ហើយឈ្មោះ [redacted] ទ្រី ជាអ្នកទៅទិញ ដោយពួកខ្ញុំបាទប្រើប្រាស់ពីល្ងាច លុះស្អែកឡើងប៉ូលីសបានមកឆែកឆេរឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងអាវុធកែច្នៃចំនួន ០៤ដើម ដោយកាំភ្លើងស្មាចំនួន ០១ដើម ជារបស់ខ្ញុំបាទ និងកាំភ្លើងបាញ់អាល់កុលចំនួន ០៣ដើម ជារបស់ឈ្មោះ ឃីម ឈ្មោះ ចាន់រ៉ា ឈ្មោះ ឡា និងឈ្មោះនឹប ដែលអ្នកទាំងបួនមកបាញ់សត្វ និងសុំទឹកខ្ញុំបាទហូប ហើយក៏ស្គាល់គ្នា ពួកគេក៏បានផ្ញើកាំភ្លើងទុកនៅរោងរបស់ខ្ញុំបាទតែម្តង ហើយរាល់ពេលគេមកបាញ់សត្វទើបគេមកយក ហើយបន្ទាប់ពីសមត្ថកិច្ចបានធ្វើការឆែកឆេរឃើញកាំភ្លើងក៏បានឃាត់ខ្លួនពួកខ្ញុំបាទតែម្តង។ ពេលខ្លះប្អូនឈ្មោះ [redacted] ទ្រី បានទៅទិញគ្រឿងញៀនពីឈ្មោះ វ៉ា ដោយខ្ញុំបាទមិនដែលទៅទិញគ្រឿងញៀនពីឈ្មោះ វ៉ា នោះទេ ហើយខ្ញុំបាទក៏មិនស្គាល់ទីលំនៅរបស់ឈ្មោះ វ៉ា ដែរ ទាល់តែឈ្មោះ [redacted] ទ្រី ទើបស្គាល់។ ចំពោះឈ្មោះ [redacted] សុងឃី ហៅ ម្រេច ជាអ្នករកស៊ីលក់ឈើ ត្រូវជាមិត្តភក្តិឈ្មោះ លីន ដោយមានលុយទិញគ្រឿងញៀនពីឈ្មោះ លីន យកមកប្រើប្រាស់ដែរ ឈ្មោះ ម្រេច ឧស្សាហ៍មកប្រើប្រាស់គ្រឿងញៀននៅចំការរបស់ខ្ញុំបាទដែរ ពីមុនមកឈ្មោះ ម្រេច ធ្លាប់លក់គ្រឿងញៀន រឺក៏អត់ គឺខ្ញុំបាទមិនដឹងទេ ព្រោះខ្ញុំបាទទើបតែស្គាល់ប្រហែលពីរខែចុងក្រោយ។ ចំពោះកាំភ្លើងស្មាជារបស់ឪពុកខ្ញុំបាទដែលគាត់ទិញមកទុកដើម្បីការពារផ្ទះហើយខ្ញុំបាទក៏យកមកប្រើប្រាស់ដើម្បីការពារនៅចំការក្នុងព្រៃ ហើយកាំភ្លើងនេះខ្ញុំបាទធ្លាប់តែបាញ់បង្គោលលេងតែប៉ុណ្ណោះ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ បានដកហូតទូរស័ព្ទម៉ាក (រឺអ៊ូ) ចំនួន ០១គ្រឿង លុយចំនួន ៧,០០០ (ប្រាំពីរពាន់) រៀល កាំភ្លើងកែច្នៃចំនួន ០៤ដើម ម៉ូតូចំនួន ០១គ្រឿងម៉ាកសេរ៉ូស ពណ៌ខ្មៅលាយក្រហម មិនចាំឆ្នាំ គ្មានស្លាកលេខ សម្ភារៈដូចជាកាំបិត ចាន ឆ្នាំង ចប់កាប់ និងមានរបស់ប្រើប្រាស់មួយចំនួនទៀត។ ដោយរយៈពេលពីរខែចុងក្រោយនេះ ក្នុងមួយថ្ងៃខ្ញុំបាទប្រើប្រាស់គ្រឿងញៀនចំនួន ០២ដង ក្នុងមួយថ្ងៃ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ [redacted]វិសិដ្ឋ ហៅ ពិសិដ្ឋ បានឆ្លើយថា: សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងជាង ១០ព្រឹក ដោយសារនៅថ្ងៃទី២៤ ពួកខ្ញុំបាទមានគ្នា ០៧នាក់

មានឈ្មោះ [redacted] វិសាល, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ថារិទ្ធ, ឈ្មោះ [redacted] បូរី, ឈ្មោះ [redacted] ទ្រី និង ឈ្មោះ [redacted] វិសែន បាននាំគ្នាប្រើប្រាស់គ្រឿងញៀននៅក្នុងរោងចំការអំពៅរបស់ខ្ញុំបាទ ដោយគ្រឿងញៀនដែលប្រើប្រាស់នោះ ខ្ញុំបាទមិនដឹងថាទិញពីអ្នកណានោះទេ ព្រោះបងប្រុសរបស់ខ្ញុំបាទឈ្មោះ [redacted] វិសាល ជាអ្នកទិញមក ដោយខ្ញុំបាទមិនបានចូលលុយគ្នាទិញនោះទេ លុះស្អែកឡើងប៉ូលីសបានមកឆែកឆេរនៅចំការរបស់ខ្ញុំបាទ ឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន និងអាវុធកែច្នៃចំនួន ០៥ដើម ដោយមានកាំភ្លើងស្មាចំនួន ០១ដើម ជារបស់ប្អូនខ្ញុំបាទឈ្មោះ [redacted] វិសែន និងកាំភ្លើងបាញ់អាកុលចំនួន ០៤ដើម មិនដឹងថា ជារបស់អ្នកណាទេ តែលឺប្អូនប្រាប់ថា មានគេផ្ញើ ហើយសមត្ថកិច្ចក៏បានឃាត់ខ្លួនពួកខ្ញុំបាទតែម្តង។ ខ្ញុំបាទមិនសូវស្គាល់ឈ្មោះ **លីន** ហើយឈ្មោះ **វ៉ា** នោះទេ ដោយធ្លាប់តែលឺបងប្រុសរបស់ខ្ញុំបាទឈ្មោះ [redacted] **វិសាល** ប្រាប់ថា អ្នកទាំងពីរជាអ្នកលក់ដូរគ្រឿងញៀន ចំណែកឈ្មោះ **ម្រេច** ខ្ញុំបាទមិនដែលស្គាល់នោះទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ បានដកហូតទូរស័ព្ទម៉ាកណូគាពណ៌ ក្រហមចំនួន ០១គ្រឿង ក្រៅពីនេះមិនមានដកហូតអ្វីផ្សេងពីខ្ញុំបាទនោះទេ។ ខ្ញុំបាទចេះប្រើប្រាស់គ្រឿងញៀនបានរយៈពេល ០៣ឆ្នាំមកហើយច្រើនរាប់មិនអស់ ដោយខ្ញុំបាទឱ្យបងឈ្មោះ [redacted] **វិសាល** ជាអ្នកទៅយកឱ្យដោយខ្ញុំបាទមិនដែលទៅទិញខ្លួនឯងនោះទេ ហើយខ្ញុំបាទមិនដែលធ្លាប់លក់គ្រឿងញៀននោះដែរ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ [redacted] នូ បានឆ្លើយថា: ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានមេធាវីការពារទេ។ សមត្ថកិច្ចឃាត់ខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោង១២ ថ្ងៃត្រង់ ដោយពីលាច ថ្ងៃទី២៤ ពួកខ្ញុំបាទមានគ្នា ០៧នាក់ មានរូបខ្ញុំបាទ, ឈ្មោះ [redacted] **វិសិដ្ឋ**, ឈ្មោះ [redacted] **បូរី**, ឈ្មោះ [redacted] **ថារិទ្ធ**, ឈ្មោះ [redacted] **វិសែន**, ឈ្មោះ [redacted] **ទ្រី** និងឈ្មោះ **សាល** ដោយបានចូលលុយគ្នាទិញគ្រឿងញៀនពីឈ្មោះ **លីន**។ ខ្ញុំបាទមិនសូវស្គាល់ឈ្មោះ **លីន** ច្បាស់នោះទេ។ គ្រឿងញៀនដែលប្រើនោះ គឺទិញក្នុងតម្លៃ ៥០,០០០ (បួនម៉ឺន) រៀល ហើយឈ្មោះ **លីន** ជាអ្នកយកមកឱ្យដល់កន្លែងចំការតែម្តង ដោយឈ្មោះ **សាល** ជាម្ចាស់ចំការជាអ្នកទូរស័ព្ទទៅទិញ ចំណែកឈ្មោះ **វ៉ា** ខ្ញុំបាទស្គាល់មិនសូវច្បាស់នោះទេ ហើយខ្ញុំបាទទៅចំការរបស់ឈ្មោះ [redacted] **វិសែន** គឺខ្ញុំបាទដឹងថាកន្លែងនោះជាកន្លែងទិញលក់គ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនដែរ ខ្ញុំបាទ ទៅប្រើប្រាស់គ្រឿងញៀននៅទីនោះបានប្រហែល ០៥ដង មកហើយ។ លុះដល់ថ្ងៃសមត្ថកិច្ចឃាត់ខ្លួន គឺខ្ញុំបាទមកពីផ្ទះបានជិះ រ៉ឺម៉កចូលទៅក្នុងចំការរបស់ឈ្មោះ [redacted] **វិសែន** ដើម្បីអង្គុយលេង ស្រាប់តែសមត្ថកិច្ចចូលមកឆែកឆេរឃើញមានកាំភ្លើងកែច្នៃ ០៥ដើម ជារបស់ម្ចាស់ចំការឈ្មោះ [redacted] **វិសែន** ឈ្មោះ [redacted] **វិសិដ្ឋ** និងឈ្មោះ **សាល** និងឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន ហើយសមត្ថកិច្ចឃាត់ខ្លួនពួកខ្ញុំបាទតែម្តង។ ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទបានដកហូតទូរស័ព្ទអិនចុចពិលចំនួន ០១គ្រឿង បារី ០៣ដើម និង

ដែកកេះចំនួនមួយ ក្រៅពីនេះមិនមានដកហូតអ្វីផ្សេងទៀតទេ។ ខ្ញុំបាទប្រើប្រាស់គ្រឿងញៀនយូរៗម្តង ដោយមិនសូវបានប្រើប្រាស់នោះទេ។ កន្លងមកនៅក្នុងឆ្នាំ២០១៨ ឈ្មោះ តុង ជាអ្នកបើកឡានធ្លាប់បានហៅខ្ញុំបាទឱ្យទៅជួយកើបអាចន៍មាន់ដឹកដាក់ចំការក្នុងខេត្តកំពង់ស្ពឺ លុះពេលត្រឡប់មកវិញក៏ឃើញគេមានត្រាំសសរនៅក្បែរផ្លូវចំនួន ១៣ដើម ហើយឈ្មោះ តុង បានឱ្យខ្ញុំបាទលើកដាក់ឡានដឹកយកមកកំពង់ស្ពឺ តែខ្ញុំបាទមិនដឹងថា ឈ្មោះ តុង យកទៅណាទេ ហើយនៅក្នុងឆ្នាំ២០១៨ នេះដែរ ខ្ញុំបាទឃើញឈើគេមួយដើមទំហំ ៥ ហ៊ុន គុណ មួយតឹកពីរ ប្រវែង ៦ម៉ែត្រ ឃើញនៅក្នុងបឹង រួចខ្ញុំបាទក៏លើយកមកផ្ទះ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ [redacted] ទ្រី បានឆ្លើយថា: ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានមេធាវីការពារទេ។ សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោង ៩ព្រឹក ពេលនោះខ្ញុំបាទទៅដូរហ្គាសដាំបាយ បានជួបជាមួយប៉ូលីស ភ្លាមនោះប៉ូលីសបានសួរថាខ្ញុំបាទទៅណា ខ្ញុំបាទឆ្លើយថាទៅដូរហ្គាស បន្ទាប់មកប៉ូលីសឱ្យខ្ញុំបាទអង្គុយមួយសន្ទុះប៉ូលិសបានដាក់ខ្នោះ ហើយនាំខ្ញុំបាទទៅចំការរបស់បងថ្លៃឈ្មោះ សាល ត្រូវជាបងប្អូនបង្កើតរបស់ឈ្មោះ [redacted]វិសែន តែឈ្មោះ សាល ប៉ូលីស មិនបានឃាត់ខ្លួនបាននៅឡើយទេ នៅពេលទៅដល់ចំការខ្ញុំបាទឃើញមានប៉ូលីសនៅទីនោះស្រាប់ ហើយធ្វើការឆែកឆេរឃើញមានកាំភ្លើងកែច្នៃចំនួន ០៥ដើម ជារបស់ឈ្មោះ [redacted]វិសែន ហៅ តែម ហៅ ពៅ ក្នុងរោងចំការរបស់ឈ្មោះ [redacted]វិសែន និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ហើយសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនពួកខ្ញុំបាទចំនួន ០៦នាក់ មានរូបខ្ញុំបាទ, ឈ្មោះ [redacted]វិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted]ថារិទ្ធ, ឈ្មោះ [redacted]បូរី និងឈ្មោះ [redacted]វិសែន តែម្តង។ ពួកខ្ញុំបាទទាំង ០៦នាក់ខាងលើ បានចូលលុយគ្នាទិញគ្រឿងពីឈ្មោះ លីន ចំនួន ០២ កញ្ចប់ តម្លៃ ៥០,០០០ (ប្លនម៉ឺន) រៀល ដោយឈ្មោះ លីន យកមកឱ្យដល់កន្លែងចំការតែម្តង មានឈ្មោះ ម្រេច ជាអ្នកទូរស័ព្ទទិញ ហើយឈ្មោះ ម្រេច រត់គេខ្លួនបាត់ហើយ។ ចំពោះឈ្មោះ វ៉ា ខ្ញុំបាទមិនដែលទៅទិញគ្រឿងញៀនពីគាត់ទេ តែឈ្មោះ លីន គាត់ទៅទិញពីឈ្មោះ [redacted]វ៉ា (វ៉ា)។ ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទមិនបានដកហូតអ្វីពីខ្ញុំបាទនោះទេ ហើយក្នុងមួយអាទិត្យខ្ញុំបាទប្រើប្រាស់គ្រឿងញៀនចំនួន ០២ដង។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-ជនជាប់ចោទឈ្មោះ [redacted] ថារិទ្ធ បានឆ្លើយថា: ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានមេធាវីការពារទេ។ សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោង ១២ ថ្ងៃត្រង់ ដោយពីល្ងាច ថ្ងៃទី២៤ ខ្ញុំបាទមានគ្នា ០៧នាក់ មានរូបខ្ញុំបាទ, ឈ្មោះ [redacted]វិសិដ្ឋ, ឈ្មោះ [redacted] បូរី, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted]វិសែន, ឈ្មោះ [redacted] ទ្រី និងឈ្មោះ សាល ដោយឈ្មោះ [redacted]វិសែន បានចូលលុយគ្នាទិញគ្រឿងញៀនពីឈ្មោះ លីន ដោយទិញតម្លៃ ៣០,០០០ (បីម៉ឺន) រៀល ដោយឈ្មោះ លីន ជាអ្នកយកមកឱ្យដល់កន្លែងចំការតែម្តង ដោយឈ្មោះ សាល ជាម្ចាស់ចំការជាអ្នកទូរស័ព្ទទៅទិ

ញ។ ខ្ញុំបាទធ្លាប់ស្គាល់ឈ្មោះ លីន ចំណែកឈ្មោះ វ៉ា ក៏ជាអ្នកលក់គ្រឿងញៀនដែរ តែខ្ញុំបាទមិនដែលទិញពីគាត់នោះទេ ដោយមិត្តភក្តិខ្ញុំបាទធ្លាប់ទៅទិញគ្រឿងញៀនពីឈ្មោះ វ៉ា ។ ខ្ញុំបាទដឹងថា នៅចំការរបស់ឈ្មោះ [redacted] វិសែន ជាកន្លែងទិញលក់គ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនដែរ ខ្ញុំបាទនៅទីនោះដោយជួយចាំចំការបងឈ្មោះ [redacted] វិសែន ដោយក្នុងមួយអាទិត្យខ្ញុំបាទប្រើប្រាស់គ្រឿងញៀន០៣ទៅ០៤ដង ដោយបងឈ្មោះ សាល ជាអ្នកឱ្យខ្ញុំបាទប្រើប្រាស់។ នៅពេលសមត្ថកិច្ចទៅដល់ចំការរបស់ឈ្មោះ [redacted] វិសែន ឆែកឆេរឃើញមានកាំភ្លើងកែច្នៃចំនួន ០៥ដើម ជារបស់ម្ចាស់ ចំការឈ្មោះ [redacted] វិសែន ឈ្មោះ [redacted] វិសិដ្ឋ និងឈ្មោះ សាល និងឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន ហើយសមត្ថកិច្ចឃាត់ខ្លួនពួកខ្ញុំបាទតែម្តង។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទមិនបានដកហូតអ្វីពីខ្ញុំបាទនោទេ។ ខ្ញុំបាទសុំសំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វិសែន និងជនជាប់ចោទឈ្មោះ [redacted] វិសិដ្ឋ បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] វិសែន ហៅពៅ និងឈ្មោះ [redacted] វិសិដ្ឋ ហៅ [redacted] ពិសិដ្ឋ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត។ ពាក់ព័ន្ធនឹងបទចោទប្រកាន់ខាងលើចំពោះបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺកូនក្តីខ្ញុំបាទបានទទួលស្គាល់អំពើប្រព្រឹត្តតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌មកម៉្លេះ ពុំដែលបដិសេធនៅដំណាក់កាលណាសោះឡើយ។ ប្រការនេះបញ្ជាក់ឲ្យឃើញអំពីស្មារតីភ្ញាក់រលឹកដឹងអំពីទោសកំហុសរបស់ខ្លួនហើយក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិខ្ញុំបាទស្នើសុំឲ្យ **លោកចៅក្រមជំនុំជម្រះ** ផ្តល់ស្ថានសម្រាលទោសតាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌដោយអនុគ្រោះ។ ដោយឡែកចំពោះបទល្មើស **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** វិញ ខ្ញុំបាទពិនិត្យឃើញថា: ចម្លើយដាក់បន្ទុករបស់ជនជាប់ចោទដទៃមកលើកូនក្តីខ្ញុំបាទថា: អាវុធដែលសមត្ថកិច្ចបានធ្វើការដកហូតគឺជារបស់ឈ្មោះ [redacted] វិសិដ្ឋ និងឈ្មោះ [redacted] **វិសែន** ដែលខុសពីចម្លើយដែលពួកខ្លួនបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ថា: អាវុធដែលសមត្ថកិច្ចបានធ្វើការដកហូតគឺជារបស់ឈ្មោះលីន និងឈ្មោះ ម្រេច ទៅវិញ។ នេះគឺជាចម្លើយដែលប្រើប្រួលក្នុងដំណាក់កាលចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលចម្លើយនេះគឺមិនអាចយកជាការបានទេ ដោយសារចម្លើយរបស់ជនជាប់ចោទផ្សេងៗដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ គឺជាចម្លើយដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ប៉ុន្តែពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង គឺពុំមានភស្តុតាងណាដែលមានតម្លៃគតិយុត្តទេ ពោលគឺគ្រាន់តែជាការអះអាងជាសម្តីតែប៉ុណ្ណោះ ដែលគ្មានភស្តុតាងមកបញ្ជាក់បានថាអង្គហេតុនេះគឺមានវិមតិសង្ស័យដោយផ្អែកតាមមាត្រា៣៨ វាក្យខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិថា **វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ**។

-លោកមេធាវី [redacted] ជាគ្រូកម្មសិក្សាបានធ្វើសេចក្តីសន្និដ្ឋានថា: ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់លោកមេធាវីកម្មសិក្សា [redacted] ទាំងស្រុង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំណុចភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ពិតជាមានករណី ប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ដែលបង្កដោយជនជាប់ចោទ ១.ឈ្មោះ [redacted] បូរី ហៅតឿ ២.ឈ្មោះ [redacted] វិសែន ហៅ តែម ហៅ ពៅ ៣.ឈ្មោះ [redacted] វិសិដ្ឋ ហៅ ពិសិដ្ឋ ៤.ឈ្មោះ [redacted] នូ ៥.ឈ្មោះ [redacted] ទ្រី និង៦.ឈ្មោះ [redacted] ថារិទ្ធ ពិតប្រាកដមែន ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាម មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ ដូច្នេះ ក្នុងនាមយើងជាតំណាងអយ្យការ គឺយើងសូមតំកល់ការចោទប្រកាន់របស់យើងដូចមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ ៣៤៥១ អ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ទុកជាបានការទាំងស្រុង និងប្តឹងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានពិនិត្យសំណុំរឿង ឯកសារ និងភស្តុតាង។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ។

-ក្រោយពីបានធ្វើការពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

សាលាដំបូងខេត្តកំពង់ស្ពឺ

យល់ឃើញថា

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បូរី ហៅតឿ, ឈ្មោះ [redacted] វិសែន ហៅ តែម ហៅ ពៅ, ឈ្មោះ [redacted] វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ ពិតជាបានប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត នៅភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ដោយត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនជនជាប់ចោទ រួមទាំងវត្ថុតាងជាក់ស្តែងនៅនឹងកន្លែង ពិតប្រាកដមែន គប្បីតុលាការលើកយកមកពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បូរី ហៅតឿ, ឈ្មោះ [redacted] វិសែន ហៅ តែម ហៅពៅ, ឈ្មោះ [redacted] វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ ពួកខ្លួនពិតជាបាន ប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ពិតប្រាកដមែន គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ូរី ហៅតឿ, ឈ្មោះ [redacted]វិសែន ហៅ តែម ហៅពៅ, ឈ្មោះ [redacted]វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ កាំភ្លើងស្មារចំនួន០១ដើម គឺជារបស់ឈ្មោះ [redacted] វិសែន ហៅតែម ហៅពៅ ចំណែកឯអាវុធកែឆ្នៃដទៃទៀតគឺជារបស់អ្នកដ៏ទៃបានផ្ញើទុកនៅក្នុងចម្ការតែប៉ុណ្ណោះ មិនពាក់ព័ន្ធនឹងពួកខ្លួនទេ គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] ប៊ូរី ហៅតឿ, ឈ្មោះ [redacted]វិសែន ហៅ តែម ហៅពៅ, ឈ្មោះ [redacted]វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ ជានីតិជន មានការយល់ដឹងសមរម្យ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើ ដែលខ្លួនបានប្រព្រឹត្ត ដែលទង្វើនេះធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម ហើយអំពើនេះត្រូវតែផ្តន្ទាទោសតាមច្បាប់ គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-មានធាតុផ្សំ និងភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] ប៊ូរី ហៅតឿ, ឈ្មោះ [redacted]វិសែន ហៅ តែម ហៅពៅ, ឈ្មោះ [redacted]វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ ពីបទៈ ប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សូមតំកល់ការចោទប្រកាន់របស់ខ្លួនដូចមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ ៣៤៥១ អ.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ទុកជាបានការទាំងស្រុង និងប្តឹងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] ប៊ូរី ហៅតឿ, ឈ្មោះ [redacted] វិសែន ហៅ តែម ហៅពៅ, ឈ្មោះ [redacted] វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ បានឆ្លើយសារភាពទទួលស្គាល់ទោសកំហុសរបស់ខ្លួននៅគ្រប់ដំណាក់ មិននាំឲ្យមានការលំបាកដល់នីតិវិធីរបស់តុលាការទេ គប្បីតុលាការពិចារណាលើកយកស្ថានសម្រាលទោស មកពិចារណាក្នុងការសម្រេចសេចក្តី ។

Scanned with CamScanner

យល់ឃើញថា

-សំណូមពរចុងក្រោយរបស់ជនជាប់ឈ្មោះ [redacted] បូរី ហៅតឿ, ឈ្មោះ [redacted] វិសែន ហៅ តែម ហៅ ពៅ, ឈ្មោះ [redacted] វិសិដ្ឋ ហៅ ពិសិដ្ឋ, ឈ្មោះ [redacted] នូ, ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ថារិទ្ធ សុំឲ្យ តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] ថារិទ្ធ ស្ថិតនៅក្នុងភាពជាអនីតិជន គប្បីតុលាការលើកយក មាត្រា ៤៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មកធ្វើការពិនិត្យ និង ពិចារណាក្នុងការសម្រេចសេចក្តី ។

យល់ឃើញថា

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសែន ហៅតែម ហៅពៅ** និងឈ្មោះ [redacted] **វិសិដ្ឋ ហៅពិសិដ្ឋ** នាពេលសវនាការថា: ចំពោះបទល្មើសប្រើប្រាស់ដោយខុសច្បាប់នូវ សារធាតុញៀន គឺកូនក្តីរបស់ខ្លួនមានស្មារតីភ្ញាក់រលឹកដឹងអំពីទោសកំហុសរបស់ខ្លួនហើយ ស្នើសុំឲ្យ **លោកចៅក្រមជំនុំជម្រះ** ផ្តល់ស្ថានសម្រាលទោសតាមបញ្ញត្តិ មាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្ម ទណ្ឌដោយអនុគ្រោះ ដោយឡែកចំពោះបទល្មើស កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត វិញ មេធាវី ការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំឲ្យ **លោកចៅក្រមជំនុំជម្រះ** ឲ្យកូនក្តីរបស់ខ្លួនឈ្មោះ [redacted] **វិសែន ហៅតែម ហៅពៅ** និងឈ្មោះ [redacted] **វិសិដ្ឋ ហៅពិសិដ្ឋ** បានរួចផុតពីបទចោទ ដោយផ្អែកតាម មាត្រា៣៨ វាក្យខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា **វិមតិសង្ស័យ** ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចក្តីតាមការ ស្នើសុំរបស់មេធាវីការសិទ្ធិឲ្យជនជាប់ចោទ។

យល់ឃើញថា

-វត្ថុតាងរួមមាន:

១.ម៉ូតូម៉ាក សេរ៉ូ ពណ៌ខ្មៅ ចាស់ទ្រុឌទ្រោម គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន RLCS5C6GOEY0 ចំនួន ០១គ្រឿង គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

២.ម៉ូតូម៉ាក ណូសា ពណ៌ស គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន 1DR056914 ចំនួន ០១ គ្រឿង គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

៣.ម៉ូតូម៉ាក គុប៥០ ពណ៌ទឹកប៊ិច គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន 050E178210 គប្បី តុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

៤.ទូរស័ព្ទដៃម៉ាក ណូគា (អិនចុចពិល) ពណ៌ខ្មៅ ចំនួន ០១គ្រឿង និងពណ៌ក្រហម ចំនួន ០១ គ្រឿង គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

Scanned with CamScanner

៥.កាំភ្លើងកែច្នៃបាញ់សត្វ ចំនួន ០៤ដើម និងឧបករណ៍ប្រើប្រាស់គ្រឿងញៀន មួយចំនួន គប្បីតុលាការពិនិត្យ និងពិចារណាក្នុងការសម្រេចសេចក្តី ។

ហេតុផ្សេងៗសាលាដំបូងខេត្តកំពង់ស្ពឺ
ទិនិច្ឆ័យសេចក្តី

I.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ប៊ូរី ហៅតឿ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៨(ដប់ប្រាំបី) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន។

II.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]នូ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៨(ដប់ប្រាំបី) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន។

III.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៨(ដប់ប្រាំបី) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន។

IV.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]វិសែន ហៅ តែម ហៅ ពៅ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១២(ដប់ពីរ) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ។

V.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]វិសិដ្ឋ ហៅ ពិសិដ្ឋ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១២(ដប់ពីរ) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ។

VI.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ថារិទ្ធ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៦(ប្រាំមួយ)ខែ តែទោសនេះត្រូវព្យួរទាំងស្រុង។

-ពីបទ: ប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

VII.វត្តុតាងរួមមាន:

១.ម៉ូតូម៉ាក សេរ៉ូ ពណ៌ខ្មៅ ចាស់ទ្រុឌទ្រោម គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន RLCS5C6GOEY0 ចំនួន ០១គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ ។

២.ម៉ូតូម៉ាក ណូសា ពណ៌ស គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន 1DR056914 ចំនួន ០១ គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ ។

៣.ម៉ូតូម៉ាក គុប៥0 ពណ៌ទឹកបិច គ្មានស្លាកលេខ មានលេខតួលេខម៉ាស៊ីន 050E178210 រឹប អូសជាសម្បត្តិរដ្ឋ ។

៤.ទូរស័ព្ទដៃម៉ាក ណូគា (អិនចុចពិល) ពណ៌ខ្មៅ ចំនួន ០១គ្រឿង និងពណ៌ក្រហម ចំនួន ០១ គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ ។

៥.កាំភ្លើងកែច្នៃបាញ់សត្វចំនួន០៤ដើម និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន រឹបអូស បំផ្លាញចោល ។

VIII.សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ប៊ូរី ហៅតឿ**, ឈ្មោះ [redacted] **វីសែន ហៅ តែម ហៅ ពៅ**, ឈ្មោះ [redacted] **វិសិដ្ឋ ហៅ ពិសិដ្ឋ**, ឈ្មោះ [redacted] **នូ**, និងឈ្មោះ [redacted] **ទ្រី** កំពាំងមុខជនជាប់ ចោទឈ្មោះ [redacted] **ថារិទ្ធ** ទុកសិទ្ធិអោយប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា: [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០២កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅកំពង់ស្ពឺ,ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner